ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

11/12/2015

សាលាឧទ្ធរណ៍

សំណុំរឿងសភាស៊ើបសួរ
លេខ : ៣០៩
ចុះថ្ងៃទី ១៦-១១-២០១៥

សាលដីកា
លេខ : ៦២ក្រ.VIIសេ.អ
ចុះថ្ងៃទី ០៩-១២-២០១៥

# គាំងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើ[redacted]
ក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

សភាស៊ើបសួរបង្កើតឡើងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានបើកសវនាការជាអសាធារណៈ
នៅសាលសវនាការសាលាឧទ្ធរណ៍ថ្ងៃទី ០៩-១២-២០១៥ ដែលរេះ
សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីពិភាក្សាដេញដោលលើបណ្តឹងឧទ្ធរណ៍ នៃរឿងសភាស៊ើបសួរលេខ ៣០៩ ចុះថ្ងៃទី ១៦-១២-២០១៥ ដែលមាន :

១-ជនត្រូវចោទឈ្មោ[redacted]ហៅ រដ្ឋ) ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតភូមិពងទឹក ឃុំរកាពប្រាំ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្នចំណុចគ.ម ៣៣ ឃុំសោម ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្មោះ[redacted]ស- ម្តាយឈ្មោ[redacted]-រ- ប្រពន្ធឈ្មោះ[redacted]មានកូន០១នាក់ ។

២-ជនត្រូវចោទឈ្មោះ[redacted]ភេទស្រី មានទីលំនៅចំណុចគ.ម៣៣ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

<u>ជាប់ចោទពីបទ</u> : **វិលោភលើទំនុកចិត្តអំពើលួច និងសមគំនិត** ប្រព្រឹត្តនៅចំណុចគ.ម៣៣ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី ២៣-៧-២០១៥ តាមបញ្ញត្តិមាត្រា ៣៩១.៣៩២.៣៥៣. ៣៥៦ និង២៩នៃក្រមព្រហ្មទណ្ឌ ។





Scanned by CamScanner

I-អំពីអង្គហេតុ

កាលពីថ្ងៃទី ២៣-៧-២០១៥ ឈ្មោះ ចេះ សុផា ភេទស្រី និងកូនប្រុសឈ្មោ [redacted] ដែលជាអ្នកជួយមើលថែចំការស្រកានាគ របស់ឈ្មោះ [redacted] បាននាំគ្នាទៅលួចកាត់ទងស្រកានាគនៅក្នុងចំការរបស់ឈ្មោ [redacted] យកទៅលក់ដោយមិនបានប្រាប់អោយម្ចាស់ចំការបានដឹងដែល ។ មិនតែប៉ុណ្ណោះឈ្មោះ [redacted] ដែលជាប្តីរបស់ឈ្មោះ [redacted] ដែលមានគំនិតកេងកិបលុយរបស់ម្ចាស់ចំការក្នុងរឿងដែលម្ចាស់ចំការអោយទិញដី និងលើកទំនប់សំរាប់ទប់ទឹក ទុកប្រើប្រាស់ក្នុងចំការ និងជាអ្នកសមគំនិតក្នុងការដែលឈ្មោះ [redacted] លួចកាត់ទងស្រកានាគរបស់ឈ្មោ [redacted] ទៀតផង ។

-បានឃើញ : ដីកាសម្រេចមិនព្រមអនុញ្ញាតឱ្យនៅក្រៅឃុំលេខ ៣៣៣០ ពស/២០១៥ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចខាងក្រោម :

១-មិនអនុញ្ញាតឱ្យនៅក្រៅឃុំចំពោះជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិពងទឹក ឃុំកោះប្រាំ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅចំណុចគីឡូម៉ែត្រ៣៣ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ឪពុកឈ្មោ [redacted] ស" ម្ដាយឈ្មោ [redacted] "រ" មានប្រពន្ធឈ្មោ [redacted] មានកូន០១នាក់ ទោសពីមុន គ្មាន ជានិតិជន ។ ត្រូវចោទពីបទ រំលោភលើទំនុកចិត្តអំពើលួច និងសមគំនិត (មាត្រា៣៩១ មាត្រា៣៥៣ មាត្រា៣៥៦ និងមាត្រា២៩នៃក្រមព្រហ្មទណ្ឌ) ដែលប្រព្រឹត្តនៅចំណុចគីឡូម៉ែត្រ៣៣ ឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ។

-បានឃើញ : សេចក្ដីចម្លងបណ្ដឹងតវ៉ាលេខ ៣៦ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] សុំប្ដឹងនឹងដីកាសម្រេចមិនអនុញ្ញាតអោយនៅក្រៅឃុំលេខ ៣៣៣០ ពស ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៥ ត្រង់ចំណុចដីកាសម្រេចទាំងមូល ។

-បានឃើញ : របាយការណ៍រឿងព្រហ្មទណ្ឌ របស់ចៅក្រមរបាយការណ៍សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

-ជនត្រូវចោទឈ្មោះ [redacted] (អវត្តមាន)

-ជនត្រូវចោទឈ្មោះ [redacted] (អវត្តមាន)

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿងហេតុឡើងវិញ ។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :

-បើពិនិត្យតាមអង្គហេតុក្នុងរឿងក្ដីនេះតំណាងអយ្យការយល់ឃើញថា មិនគួរអោយឃុំខ្លួនជនត្រូវចោទទេព្រោះ ការប្រព្រឹត្តរបស់ជនត្រូវចោទជាបទល្មើសមធ្យម ព្យសនកម្មនៃការប្រព្រឹត្តរបស់ជនត្រូវចោទមានលក្ខណៈតូចតាច ជនត្រូវចោទកំពុងតែមានជំងឺលើសឈាម មានកូនតូចៗក្នុងបន្ទុកគ្រួសារ ហើយប្រពន្ធកំពុងមានផ្ទៃពោះគ្រប់ខែ ចាំបាច់ត្រូវការជនត្រូវចោទមើលថែរក្សា ចាត់ចែងក្នុងបន្ទុកគ្រួសារនិងកូនតូចៗផងដែរ ជនត្រូវចោទមានទីលំនៅ និងមុខរបរពិតប្រាកដ។ ដូច្នេះបើជនត្រូវចោទគោរពតាមលក្ខខ័ណ្ឌត្រឹមត្រូវតាមច្បាប់ សូមក្រុមប្រឹក្សាជំនុំជម្រះពិចារណា និងសម្រេចតាមច្បាប់ ។



Scanned by CamScanner

-ក្រោយពីបានស្តាប់អំនានរបាយការណ៍ ។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងបហារអយ្យការ ។
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនត្រូវចោទ ។
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។
-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានា ។
-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>**សភាស៊ើបសួរ**</u>

<u>**យល់ឃើញថា**</u> :

១-បណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់លោក[redacted]មធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ[redacted]៧ រដ្ឋ) ទៅនឹងដីកាសម្រេចមិនព្រមដោះលែងឱ្យនៅក្រៅឃុំលេខ ៣៣៣០ តព្រ/១៥ ចុះថ្ងៃទី ២២-១០-២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ គឺត្រឹមត្រូវតាមច្បាប់ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ទទួលពិភាក្សាដេញដោលបានតាមមាត្រា ២៦៧ ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ផ្អែកតាមលទ្ធផល នៃកិច្ចពិភាក្សាដេញដោលនៅសភាស៊ើបសួរសាលាឧទ្ធរណ៍ឃើញថា ៖

ក-តាមចម្លើយជនត្រូវចោទ ចម្លើយដើមបណ្តឹង និងភស្តុតាងនានា នៃសំណុំរឿងបង្ហាញឱ្យឃើញថា ជនត្រូវចោទពិតជាមានតម្រុយភស្តុតាងជាប់ពាក់ព័ន្ធ ទៅនឹងបទល្មើសពីបទ រំលោភលើទំនុកចិត្តអំពើលួច និងសមគំនិត ប្រព្រឹត្តនៅចំណុចគ.ម៣៣ ឃុំសាប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី ២៣-៧-២០១៥ តាមបញ្ញត្តិមាត្រា ៣៩១.៣៩២.៣៥៣. ៣៥៦ និង២៩នៃក្រមព្រហ្មទណ្ឌ ។ ហើយត្រូវបានចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ សម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ៣០៩១តព្រ/១៥ ចុះថ្ងៃទី ០១-១០-២០១៥ របស់ចៅក្រមស៊ើបសួរ និងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៨០៥ អយ ចុះថ្ងៃទី ៣០-០៩-២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តក្រចេះ ហើយបានផ្តន្ទាទោសដាក់ពន្ធនាគារក្នុងលក្ខខ័ណ្ឌការឃុំខ្លួនដែលមានចែងក្នុងមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ពិតមែនក៏ប៉ុន្តែដោយហេតុថា ៖

+ជនត្រូវចោទជាប់ចោទពីបទមជ្ឈឹម ព្យសនកម្មបណ្តាលមកពីបទល្មើស មានលក្ខណៈតូចតាច ។

+ជនត្រូវចោទកំពុងតែមានជំងឺលើសឈាម មានកូនតូចៗក្នុងបន្ទុកគ្រួសារ ហើយប្រពន្ធកំពុងមានផ្ទៃពោះគ្រប់ខែ ចាំបាច់ត្រូវការជនត្រូវចោទមើលថែរក្សា ចាត់ចែងក្នុងបន្ទុកគ្រួសារនិងកូនតូចៗផងដែរ ។

+ជនត្រូវចោទមានទីលំនៅ និងមុខរបរពិតប្រាកដ ។

+ដំណើរការស៊ើបសួរ មានភាពជឿនលឿន ។

+ជនត្រូវចោទពុំធ្លាប់មានទោសពីមុនមក ។

+ជនត្រូវចោទពុំមានឥទ្ធិពល តាមសង្កត់សាក្សី និងបំផ្លិចបំផ្លាញភស្តុតាងនានា ។

ដូច្នេះ បើអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំបណ្តោះអាសន្ន ក៏ពុំមានបញ្ហាអ្វីឱ្យមានការបារម្ភខ្លាចក្រែងជនត្រូវចោទបង្កឧបសគ្គដល់ដំណើរការស៊ើបសួរ ឬគេចវេស ឬការគាបសង្កត់សាក្សីឡើយ ។ម្យ៉ាងទៀត ដើម្បីបានាដល់ដំណើរការនីតិវិធីរបស់តុលាការជំនុំជម្រះ នាពេលសវនាការ សភាស៊ើបសួរគប្បីពិចារណាដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ ផ្អែកតាមស្មារតីនៃមាត្រា ២២៣ ២៣០ និងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ខ-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានលើកឡើងនាពេលពិភាក្សាដេញដោលជាអសាធារណៈ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណាផងដែរ ។



Scanned by CamScanner

## ហេតុដូច្នេះវិនិច្ឆ័យសម្រេច

១-បណ្តឹងឧទ្ធរណ៍លេខ ៣៦ ចុះថ្ងៃទី ០៣-១១-២០១៥ របស់ឈ្មោះ [redacted] មេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] គឺត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-បដិសេធចោលនូវដីកាសម្រេចមិនព្រមអនុញ្ញាតិអោយនៅក្រៅឃុំលេខ ៣៣៣០ ពស/១៥ ចុះថ្ងៃទី ២២-១០-២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តក្រចេះ ។

៣-អនុញ្ញាតិឱ្យជនត្រូវចោទឈ្មោះ [redacted] ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ រំលោភលើទំនុកចិត្តអំពើលួចនិងសមគំនិត ប្រព្រឹត្តនៅចំណុចគ.ម.៣៣ ឃុំសាម ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ កាលពីថ្ងៃទី ២៣-៧-២០១៥ តាមមាត្រា ៣៩១.៣៩២.៣៥៣.៣៥៦ និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ បាននៅក្រៅឃុំបណ្តោះអាសន្ន ។

៤-បង្គាប់ឱ្យដាក់ជនត្រូវចោទឈ្មោះ [redacted] ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវអោយអនុវត្តតាមកាតព្វកិច្ចមួយចំនួន ដូចខាងក្រោម ៖

ក-មិនត្រូវចាកចេញក្រៅព្រំប្រទល់ដែនដី នៃព្រះរាជាណាចក្រកម្ពុជា ។

ខ-មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋាន ដោយគ្មានការអនុញ្ញាតិពីចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរឡើយ ។

គ-ត្រូវបង្ហាញខ្លួនតាមការកំណត់នៅមុខតុលាការ បើមានដីកាកោះហៅពីតុលាការ ។

ឃ-ត្រូវបង្ហាញខ្លួន នៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសោប ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ក្នុង០១ខែម្តង រៀងរាល់ថ្ងៃទី ០១នៃខែនីមួយៗ ។

ករណីជនត្រូវចោទគេចវេស ដោយចេតនាមិនព្រមអនុវត្តកាតព្វកិច្ច ត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរ អាចសម្រេចចាប់ឃុំជនត្រូវចោទនេះឡើងវិញ ។

៥-សាលដីកានេះ បានពិភាក្សាដេញដោលជាអសាធារណៈនាថ្ងៃទី ០២-១២-២០១៥ និងប្រកាសជាអសាធារណៈនាថ្ងៃទី ០៩-១២-២០១៥

-បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner